INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# មិត្តសាលាបាលី

ទស្សនាវដ្តីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ



ឆ្នាំទី ១ មីនា លេខ ៣

ព. ស. ២៤៩២ — គ. ស. ១៩៥០

ទស្សនាវដ្ដីអនុមាសផ្សាយព្រះពុទ្ធសាសនានឹងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ ឈឹម-ក្រសេម

សំណាក់ការ លេខ ៣៥ ភា., វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង


| | | ទំព័រ |
|---|---|---|
| វិចារណកថា | | ៨១ |
| ព្រះពុទ្ធសាសនានឹងសេចក្ដីចំរើនក្នុងលោក | ហេង-យ៉ាន់ | ៨៣ |
| មលធម៌ | ព្រះគ្រូសិរីសោភ័ណ កិម-ទួរ | ៩០ |
| មគ្គមួយ ឬ មគ្គប្រាំបី | ពាង-ពិន | ៩៦ |
| ប្រវត្តិអ្នកព្រះភិរម្យភាសាអ៊ូ ហៅង៉ុយ | អាចារ្យ អ៊ូ-ប៊ុន | ១០២ |
| ជោគវាសនានឹងសេចក្ដីព្យាយាម | ហេង-យ៉ាន | ១០៦ |
| អត្តនោមត្យធិប្បាយ | ក្រមការ ភយ-ប៊ុក | ១១២ |
| បញ្ចគន្ធៈ | សេចក្ដីប្រែរបស់ភិក្ខុ ប៉ាង-ខាត់ | ១១៣ |
| សេចក្ដីថ្លែងការណ៍គណៈកម្មាធិការ | | ១១៧ |



ដំឡៃផ្សាវ

| | |
|---|---|
| ១ ឆ្នាំ | ៩៦,០០ |
| ១ ឆមាស | ៤៨,០០ |
| ១ ត្រីមាស | ២៤,០០ |
| ១ ក្បាល | ៨,០០ |


អ្នកអានទាំងឡាយ។ សូមអញ្ជើញចុះឈ្មោះផ្សាវ។

នឹងបបួលញាតិមិត្តជួយផ្សាវ។

ជីវិតទស្សនាវដ្ដីស្ថិតនៅលើលោកអ្នក ៗ

# វិចារណកថា

ជាតិលាវ សៀម និងខ្មែរ មានលក្ខណៈ ទ្រង់ទ្រាយ សំបុរសំបក ព្រមទាំងលទ្ធិទំនៀមទម្លាប់ និងសាសនាប្រហែលៗគ្នា, ប្រសិនជាអ្នកទាំងនេះ រួមនៅជាមួយគ្នាក្នុងទីណាមួយ ដោយស្ងាត់ស្ងៀមនោះ គេមិនអាចនឹងបង្អុលថា រូបនេះជាលាវ រូបនេះជាសៀម រូបនេះជាខ្មែរ បានឡើយ លុះត្រាតែអ្នកនោះបញ្ចេញវាចាឡើង ទើបគេស្គាល់បានថាជាជាតិនោះ ជាតិនេះ ។ ដោយហេតុនេះ ទើបលោកចងទុកជាសុភាសិតថា “ភាសា ស ជាតិ” ។ សុភាសិតនេះ បុព្វបុរសរបស់យើងបានទទួលប្រតិបត្តិនឹងក្រេបអត្ថរសឥតមានរួញរាឡើយ ដូចមានប្រាកដនៅទំព័រសាស្ត្រា – ក្រាំងរបស់ជាតិយើងជាច្រើន គួររាប់ថាជាគោលសំខាន់សម្រាប់ជាតិ ១ យ៉ាង – ។

ពោលដោយចំពោះ ក្នុងសម័យអតីតកាលដែលខ្មែរយើងកំពុងចំរើនរុងរឿង ជាប្រទេសមហាអំណាច ១ នៅក្នុងទ្វីបអាស៊ីនោះ គេបាននិយមប្រើអក្សរសាស្ត្ររបស់ជាតិក្នុងផ្លូវការមកហើយ ដូចមានប្រាកដក្នុងប្រវត្តិសាស្ត្រ សឹងមានអ្នកប្រាជ្ញប្រវត្តិសាស្ត្រជាច្រើនបានទទួលរ៉ាប់រងមកហើយផង ។

សូម្បីមានភស្តុតាងយ៉ាងនេះ យើងក៏នៅមានសេចក្តីស្តាយជាបំផុត ដែលក្នុងបច្ចុប្បន្ននេះមានអ្នករួមជាតិរបស់យើងជាច្រើននាក់ បានពេប

ជ្រាយនឹងរិះគន់ថា ភាសាខ្មែរយើងមិនល្អ មិនសំបូណ៌ល្មមនឹងប្រើការ
បាន ហើយក្រាញមិនព្រមប្រើ ។ សំដីនេះ យើងអាចដឹងបានថាជាសំដី
របស់អ្នកខ្សត់ខ្សោយសេចក្ដីបេះដូងក្នុងភាសារបស់ជាតិ អ្នកមិនស្នេហា
ជាតិ អ្នកមិនស្គាល់ប្រយោជន៍ក្នុងការប្រើអក្សរសាស្ត្ររបស់ជាតិ ជាអ្នក
មាននិស្ស័យគប់នៅក្នុងលទ្ធិដទៃជ្រៅពេកហើយ មិនងាយនឹងត្រឡប់មក
យល់ប្រយោជន៍ដ៏សំខាន់របស់ជាតិវិញទេ ។

តែទោះបីដូច្នេះក៏ដោយ យើងសូមរំលឹកជាថ្មីទៀតថាបុព្វបុរស
របស់យើង បានប្រើអក្សរសាស្ត្ររបស់ជាតិក្នុងផ្លូវការមកហើយ ដូចយ៉ាង
ព្រះរាជសារទៅប្រទេសចិន ប្រទេសចាម្ប៍ ប្រទេសជពុនជាដើម
ដូចមានប្រាកដក្នុងប្រវត្តិសាស្ត្រស្រាប់ ។ ខនេះជាការគាប់ប្រសើរហើយ
មិនគួរយើងជាអនុជនក្រោយប្តូរប្រែប្រួលទៅដោយប្រការដទៃឡើយ ។
សូមឲ្យជ្រាបថា ការប្រើអក្សរសាស្ត្ររបស់ជាតិជាករណីយកិច្ចរបស់ជាតិ
ជាកិត្តិយសយ៉ាងខ្ពស់របស់ជាតិ ជាឧត្តមគតិរបស់អ្នកប្រាជ្ញជាន់ខ្ពស់ ។

ក្នុងទីបំផុតនេះ យើងសូមឲ្យអស់លោកអ្នករួមជាតិប្រឹងប្រែងស្រាវ
ជ្រាវស័ក្យភាសាជាតិឲ្យបានហ្មត់ចត់ពល់ ៗ គ្នាឡើង ដើម្បីឲ្យសមរម្យ
តាមកាលៈទេសៈ ព្រោះថាបើយើងមិនរៀនខ្លួនយើង គេនឹងឲ្យនរណា
រៀនជួសយើង ។ ចំណែកអស់លោកអ្នកដែលចេះដឹងជ្រៅជ្រះស្រាប់
ហើយ ក៏សូមយកចិត្តទុកដាក់ផ្សាយវិជ្ជាផ្នែកនេះឲ្យបានបរិបូណ៌ ដើម្បីកុំ
ឲ្យអាប់ឱនជាងជាតិដែលនៅជិតខាង ។

ម្នាលអានន្ទ! អ្នកណាមួយ ទោះជាភិក្ខុក្តី ជាភិក្ខុនីក្តី ជាឧបាសកក្តី ជាឧបាសិកាក្តី ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីគោរពក្រែង ប្រព្រឹត្តតាមធម៌ អ្នកនោះទើបឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន និងបូជា ចំពោះតថាគត ដោយការបូជាដ៏ប្រសើរបំផុត ។

មហាបរិនិព្វានសូត្រ មហា. ទីឃ.

# ព្រះពុទ្ធសាសនានិងសេចក្តីចំរើនក្នុងលោក

សេចក្តីចំរើនខាងសម្ភារៈក្នុងលោកចេះតែមានដំណើរលឿនលឿនទៅមុខឥតស្រាក កើតវត្ថុប្រតិស្ឋវិសេសឡើងៗជាលំដាប់ ប្លែកៗគ្នាពីជំនាន់មួយទៅជំនាន់មួយ ។ រឿងនេះជាហេតុឲ្យអ្នកប្រកាន់រូបនិយមកើតអស្ចារ្យក្នុងចិត្ត ស្ញើបសរសើរបញ្ញាមនុស្សមិនដាច់មាត់ ហើយទទួលរាប់រងថា ប្រសិនបើមនុស្សលោកប្រាសចាកមហិច្ឆតា គឺសេចក្តីប្រាថ្នាធំ ពិភពលោកសព្វថ្ងៃនេះមិនខុសអ្វីនឹងសម័យបុរាណ ដែលនៅជាព្រៃផ្សៃនៅឡើយនោះទេ ។ ទីបំផុត គេបានចុះមតិថា ការប្រព្រឹត្តខ្លួនជាអ្នកប្រាថ្នាតិច តាមពាក្យប្រៀនប្រដៅក្នុងព្រះពុទ្ធសាសនា ជាទំនាស់នឹងសេចក្តីចំរើនក្នុងលោក ។

យើងជាពុទ្ធមាមកជន យើងព្រមទទួលសរសើរអស់លោក - អ្នកប្រាជ្ញដែលផ្សាយមេត្តាចិត្តក្រាលលើលោកទាំងមូល បានខំប្រឹងប្រែងស្វែងរកមធ្យោបាយ ដើម្បីតតាំងនឹងកំឡាំងសត្រូវខាងក្រៅនៃមនុស្សជាតិ ផ្តល់នូវផាសុកដល់កៀនមនុស្សឲ្យបានសុខស្រួលខាងផ្លូវកាយ ព្រោះកម្រនឹងមានអ្នកគិតដល់ប្រយោជន៍ទូទៅយ៉ាងធំទូលាយបែបនោះណាស់ ។ អ្នកដែលបានតាំងខ្លួនជាអ្នកសង្គ្រោះគេនោះ គេងឧទ្ទិសនូវពេលវេលាចំពោះកិច្ចរបស់ខ្លួន គឺការកំសាន្តនានាព្រមទាំងសម្បត្តិទ្រព្យរហូតដល់អាយុសង្ខារផង ។ តែយើងនឹកអស់សំណើចត្រង់សំដីថាព្រះពុទ្ធសាសនាជាទំនាស់នឹងដំណើរសេចក្តីចំរើនរបស់លោក ផ្ទុយនឹងសេចក្តីយល់របស់យើង ដែលទុកព្រះពុទ្ធសាសនាជាមធ្យោបាយដ៏ប្រពៃសំរាប់ស្វែងរកសេចក្តីចំរើន ។

សព្វថ្ងៃនេះ យើងស្ថិតក្នុងយុគនៃការបរិវត្តន៍ខាងវិទ្យាសាស្ត្រដែលនាំមកនូវវឌ្ឍនធម៌ដ៏សម្បើមអស្ចារ្យ ។ ជីដូនជីតារបស់យើងមិនបាននឹកស្រមៃថា លោកនឹងប្រែសភាពបែបនេះដល់ម្ដងទេ គួរឲ្យស្ញើបបញ្ញាមនុស្សមែន កាលសម័យព្រេងនាយ នៅក្នុងសភាពអនារ្យគឺព្រៃផ្សៃនៅឡើយ បុព្វបុរសរបស់យើងជ្រកកោនបំពួនអាត្មានៅក្នុងគុហា ពុំមានអ្វីជាគ្រឿងការពារខ្លួនទេ យកស្បែកម្រឹគដែលសម្លាប់បានមកធ្វើជាសំលៀកបំពាក់ ប្រើថ្មជាអាវុធជាឧបករណ៍ មានសត្រូវបៀតបៀនជុំទិស

គឺសត្វសាហាវយង់ឃ្នង, ភ្លៀងផ្គររន្ទះនឹងក្ដៅត្រជាក់ជាដើម ។ ការស្វែងរកអាហារចិញ្ចឹមជីវិតក៏ពិបាក ព្រោះត្រូវកាប់សម្លាប់សត្វដោយគ្រឿងកំពេលមិនមុតល្អ ជួនកាលប្រទះសត្វដែលខ្លាំងលុបមាឌផង ឬត្រូវស្ទាក់រកទៅទីឆ្ងាយពីលំនៅ ។ កាលណោះ ពុំមានសណ្ដាប់ធ្នាប់នៅឡើយ គេកាន់ច្បាប់អ្នកខ្លាំងពូកែ ឃើញថា ជនជាន់នោះមានសភាពគួរឲ្យវេទនាណាស់ ស្គាល់លោកតែក្នុងមួយកំលុងនៃតំបន់របស់ខ្លួនប៉ុណ្ណោះ ទើបគេនិយមទុកជនជាន់នោះដូចជាសត្វសាហាវ ។ តែមនុស្សជាតិ ដោយសេចក្ដីត្រូវការចង់បានល្អ ចង់បានប្រសើរ ចង់បានសុខស្រួល ក៏បានប្រែប្រួលសភាពលោកជាលំដាប់ៗមក ។ ផែនដីដែលក្រៀមក្រោះប្រែក្លាយជាសួនច្បារ ជាស្រែចម្ការខៀវស្រងាត់ បរិបូណ៌ដោយគេហដ្ឋានប្លែកៗ ប្រសព្រំដែរ ជាសង្កាត់ខ្វែងដោយផ្លូវតូចផ្លូវធំនឹងយានជំនិះយ៉ាងលឿនៗ ។ គេអាចត្រាច់កាត់ពីស្រុកមួយទៅស្រុកមួយបានដោយងាយរហ័ស ។ ដំណឹងនៅតំបន់ឆ្ងាយអាចផ្សាយទៅមកក្នុងរយៈវេលាយ៉ាងខ្លី គឺពេលលូកដៃទៅមូលទ្រនិចវិទ្យុ ។ គ្រឿងបរិភោគឧបភោគនឹងផាសុកគ្រប់មុខសម្បូណ៌ពោរពាស ។ បើនិយាយឲ្យខ្លីទៅ លោកសព្វថ្ងៃប្រែជាវិមានទិព្វសំរាប់ជនសម័យបុរាណ ។ ឃើញជាក់ថាបានទទួលសេចក្ដីចំរើនប្រាកដមែន គួរឲ្យស្ងើចអស្ចារ្យពិត ។

តែបើយើងពិចារណាឲ្យសព្វគ្រប់អំពីប្រស្នាថា កិច្ចការរបស់យើងទាំងប៉ុន្មាន សំរេចទៅមានអ្វីជាវត្ថុបំណង ឬក៏យើងត្រូវការចង់បានអ្វី ទើបខំប្រឹងប្រែងខ្វល់ខ្វាយមិនចេះឈប់? ប្រស្នានេះ យើងឆ្លើយដោះសារបានតែមួយផ្លូវប៉ុណ្ណោះ "ធ្វើឲ្យកើតសេចក្ដីចំរើន ដើម្បីឲ្យបានសេចក្ដីសុខ, សេចក្ដីសុខដ៏ពិតប្រាកដ សេចក្ដីសុខឥតមានលាយសេចក្ដីទុក្ខ" ។ សុខនឹងកើតបាន លុះតែលែងមានសេចក្ដីខ្វះខាត សេចក្ដីព្រួយបារម្ភ ចង្អៀតចង្អល់ គឺបានទទួលសេចក្ដីស្ងប់ក្នុងចិត្ត ។

កាលសំឡឹងលោកដោយទស្សនៈបែបនោះ នឹងគួរចាត់ថា អ្នករូបនិយមបានទំលុះទំលាយប្រស្នាសេចក្ដីសុខ ដែលជាផលផ្ទាល់នៃសេចក្ដីចំរើនហើយឬនៅ? បើពិចារណាខ្លួនយើងឲ្យល្អិតល្អន់នឹងសំឡឹងមើលជុំវិញខ្លួនយើងដោយហ្មត់ចត់ទៅ ឃើញថាសេចក្ដីព្រួយបារម្ភ ចង្អៀតចង្អល់នៃបុព្វបុរសមិនបានរលត់សូន្យឈឹងបាត់ស្លាត់ក្នុងសម័យនេះទេ នៅតែមានជាប់នឹងសន្ដានចិត្តមនុស្សដដែល គ្រាន់តែប្រែប្រួលសភាពប៉ុណ្ណោះ ។ យើងមិនបានអម្ពល់ព្រោះភ្លៀងផ្គរនឹងសត្វសាហាវមែន ព្រោះមានគ្រឿងការពារគ្រប់គ្រាន់បរិបូណ៌ហើយ តែនៅបារម្ភខ្លាចអត់ឃ្លាន ខ្លាចគេដណ្ដើមទ្រព្យសម្បត្តិ ខ្លាចគេសន្ធប់សេរីភាព ខ្លាចគេប្រើគ្រឿងផាសុកធម្មតា ជាគ្រឿងសស្ត្រាវុធសំឡាប់យើងវិញ ។ គ្រឿងប្រដាប់សំរាប់ប្រើប្រាស់ធម្មតាណាមួយ ដែលគេមិនអាចនឹងកែតាមយថាសភាវជា

យុទ្ធោបករណ៍បាន? កប៉ាល់ហោះជា យានលឿន យានគ្រាប់បែកទៅកំទេចបន្ទាយខ្មាំង ។ វិទ្យុសំរាប់ផ្សាយដំណឹងពិតប្រែក្លាយជាគ្រឿងបង្ហិលខួរ រហូតដល់វត្ថុបភោគដែលជាផលនៃសេចក្តីចំរើនរបស់អ្នករូបនិយម ក៏អាចប្រើជាគ្រឿងវិនាសបាន ។ យើងនៅព្រួចព្រឺអំពីឫទ្ធិនៃគ្រាប់បែកបរមាណូនៅឡើយ ឥឡូវនេះ គេគំរាមលោកដោយគ្រាប់បែកហ៊ីដ្រូហ្សែនទៀត ។ ទាំងនេះបញ្ជាក់ឲ្យឃើញថា សេចក្តីភ័យក្នុងសម័យនេះសម្បើមជាងសម័យបុរាណជាពាន់គុណ ។ បើពោលពីសុខ-ភាពវិញ ជនសម័យបុរាណមានកាយមាំមួនល្អ និងអាយុវែងជាងសម័យបច្ចុប្បន្ន ។

សេចក្តីអធិប្បាយខាងលើនេះ មិនបានផ្តល់ទៅលើការលើកទោសអស់លោកអ្នកវីរៈបុរសដែលបានខំកសាង សេចក្តីចំរើនក្នុងលោកខាងផ្លូវកាយនោះទេ ។ តក្កវត្តជាកេរ្តិ៍ដំណែលរបស់លោកដែលប្រែក្លាយចាកការបំរុងតាមបំណងដើមទៅជាគ្រឿងសំរាប់បង្កបង្កើតសេចក្តីវិនាសវិញនោះ ខុសមកពីអ្នកប្រើប្រាស់មានគំនិតអាក្រក់ទេ ។ មនុស្សយើងពុំមានត្រឹមតែរាងកាយសំរាប់លេងសប្បាយ និងបរិភោគអាហារប៉ុណ្ណោះទេ គឺមានចិត្តជាអ្នកត្រួតត្រាបង្គាប់បញ្ជាជាអ្នកឲ្យនូវទុក្ខនិងសុខ និងទទួលនូវទុក្ខនិងសុខនោះទៀតផង ។

ការលោតទៅតាមកំឡាំងសេចក្ដីត្រេកអររបស់រាងកាយ ជាការប្រព្រឹត្តតាមសភាវគតិឥតងឹតងល់ ដូចគ្នានឹងសន្ដានធម្មតានៃសត្វ មិនបានរួញរាចំពោះមធ្យោបាយដែលត្រូវប្រើទេ តែមនុស្សមានបញ្ញាជាគ្រឿងផ្ទុះបំភ្លឺ ជាគ្រឿងទប់នូវសភាវគតិ លើកឋានៈឲ្យវិសេសជាងតិរច្ឆាន ។ អាស្រ័យបញ្ញានេះ យើងអាចរិះគិតរកហេតុផល សព្វវិជ្ជាផ្សេង ៗ សំរាប់កំចាត់បង់នូវសេចក្ដីងឹតងល់ ពោលគឺអវិជ្ជារបស់លោកបាន ដូច្នេះគប្បីអប់រំឲ្យចិត្តផង ទើបទទួលសេចក្ដីចំរើនបានបរិបូណ៌ ។

ការបង្វឹកបង្ហាត់ចិត្តឲ្យបានបទ ការចំរើនបញ្ញា ត្រិះរិះរកផ្លូវល្អឬអាក្រក់ ការកំចាត់នូវសេចក្ដីងឹតងល់ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធសាសនា ។ រឿងនេះ យើងបានអធិប្បាយក្នុងលេខ ២ មកហើយ បានបង្ហាញឲ្យឃើញថា ព្រះពុទ្ធសាសនាញុំាងអ្នកកាន់តាមឲ្យថ្លៃថ្នូរ ឲ្យតាំងខ្លួនជាមនុស្សជាតិពេញលេញ ។ ព្រះពុទ្ធសាសនាពុំមែនផ្ដៀងទៅលើចិត្តនិយមឬធម្មនិយមតែម្ខាងទេ បានក្រើនរំលឹកឲ្យបណ្ដុះខាងរូបនិយមផង ។ ព្រះសម្មាសម្ពុទ្ធបានតាំងព្រះអង្គជាទិដ្ឋានុគតិស្រាប់ កាលទ្រង់ពិសោធឃើញការបំពេញទុក្ករកិរិយាមិនបានប្រយោជន៍ ព្រះអង្គបានចំរើនព្រះសរីរៈឲ្យមានសុខភាពល្អ ជាឧបករណ៍ដ៏សំខាន់សំរាប់ការបដិវត្តន៍ចិត្ត ។ ដូច្នេះ ព្រះពុទ្ធសាសនាពុំបានហាម

ប្រាមក្នុងការអេបស្ទបពងកាយទេ តែបានបង្ហាញនូវមធ្យោបាយឥតទោស គឺឲ្យមានសេចក្ដីសន្ដោសសំរាប់ឃាត់ឃាំងសេចក្ដីលោភ មិនឲ្យប្រឡាតរាតអាតទៅប៉ះពាល់ដល់អ្នកជិតខាង ឲ្យស្វែងរកប្រយោជន៍ខ្លួនព្រមទាំងប្រយោជន៍អ្នកដទៃ ។ គុណធម៌ទាំងនេះជាអង្គនៃសន្តិសុខញ៉ាំងមនុស្សឲ្យក្សេមក្សាន្ត បាត់ព្រួយបារម្ភបង្អើតចង្អល់ចិត្ត ។ ព្រះពុទ្ធជាម្ចាស់ពិតជាកំពូលអ្នកប្រាជ្ញធ្វើលោកឲ្យចំរើន ទ្រង់ណែនាំផ្លូវសត្វលោកឲ្យដើរទៅកាន់វឌ្ឍនធម៌ដ៏ខ្ពង់ខ្ពស់ ទ្រង់ចង្អុលប្រាប់ក្នុងបរាភវសូត្រនូវសេចក្ដីវិនាសនឹងសេចក្ដីចម្រើន ។

ដូច្នេះ ការធ្វើសេចក្ដីចំរើនតែខាងរូបនិយមម្យ៉ាង អាចនាំនូវសេចក្ដីវិនាសមកឲ្យខុសចាកបំណងដើម គប្បីចំរើនខាងផ្លូវចិត្តនិយមផង ទើបបានទទួលនូវសេចក្ដីចំរើនពិតប្រាកដ ។ ព្រះពុទ្ធសាសនាបានដាស់តឿនឲ្យធ្វើសេចក្ដីចំរើនទាំង ២ ផ្លូវ ; ទឹងទុកសាសនានេះជាចំរូងដល់សេចក្ដីចំរើនក្នុងលោកតាមសេចក្ដីយល់របស់អ្នករូបនិយម ពុំសមហេតុសមផលទេ ។ ព្រះពុទ្ធសាសនាពិតជាមធ្យោបាយ ដ៏ប្រសើរសំរាប់បង្កើតសេចក្ដីចំរើន សេចក្ដីសុខដ៏ធំទូលាយក្នុងលោក ប្រាកដជាភាជន៍សំរាប់ទ្រទ្រង់នូវសេចក្ដីចំរើន ។

ហេង - យ៉ាន់

# មលធម៌

មលធម៌មាន ៨ ប្រការ គឺ:

១– អសជ្ឈាយមលា មន្តា មន្តទាំងឡាយមានការមិនស្វាធ្យាយជាមន្ទិល ។

២– អនុដ្ឋានមលា ឃរា ផ្ទះទាំងឡាយមានការមិនដុសដុលជាមន្ទិល ។

៣– មលំ វណ្ណស្ស កោសជ្ជំ សេចក្ដីខ្ជិលជាមន្ទិលរបស់សម្បុរ ។

៤– បមាទោ រក្ខតោ មលំ សេចក្ដីធ្វេសប្រហែសជាមន្ទិលរបស់អ្នករក្សាទ្រព្យ ។

៥– មលិត្ថិយា ទុច្ចរិតំ ការប្រព្រឹត្តអាក្រក់ជាមន្ទិលរបស់ស្ត្រី ។

៦– មច្ឆេរំ ទទតោ មលំ សេចក្ដីកំណាញ់ជាមន្ទិលរបស់អ្នកឲ្យ ។

៧– មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច បាបធម៌ទាំងឡាយ ជាមន្ទិលក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

៨– តតោ មលា មលតរំ អវិជ្ជា បរមំ មលំ អវិជ្ជាជាមន្ទិលដ៏ក្រៃលែងជាងមន្ទិលទាំងអស់នោះទៅទៀត ។

មន្តទាំងឡាយមានការមិនស្វាធ្យាយជាមន្ទិល = មន្តគឺវិជ្ជាខាងផ្លូវលោកក្តី ខាងផ្លូវធម៌ក្តី ដែលនរជនបានសិក្សារៀនសូត្របេះដឹងម៉ត់ចត់ ហើយបើឧស្សាហ៍រំឭករឿយៗ នឹងរឹងរិតតែចាំស្ទាត់ជំនាញឡើង ជាគុណប្រយោជន៍ធំទូលាយណាស់ ដល់កាលណាត្រូវការប្រើ ៗ បើរៀនចេះដឹងស្ទាត់ប្រាកដហើយ ខ្ជិលច្រអូសបណ្តែតបណ្តោយមិនខំព្យាយាមរំឭកបន្ថែមទៀតទេ មិនយូរប៉ុន្មាន មន្តគឺវិជ្ជានោះនឹងវិនាសអន្តរាយទៅវិញ ជាមន្ទិលជាទោសគឺភ្លេចបាត់បង់ប្រើការមិនកើត នាំឲ្យក្តៅក្រហាយស្តាយក្រោយ, ព្រោះហេតុនោះ បានជាព្រះបរមលោកនាថទ្រង់សំដែងថា "មន្ត គឺវិជ្ជា ទាំងឡាយមានការមិនស្វាធ្យាយជាមន្ទិល" ។

ផ្ទះទាំងឡាយមានការមិនជួសជុលជាមន្ទិល = គេហដ្ឋានទីលំនៅជាប្រក្រតី បើមានការធ្លុះធ្លាយពុកបាក់បែកខ្ទះបន្តិចបន្តួចហើយអើពើថែទាំ ឆាប់ជួសជុលទល់ទ្រ ទើបទីលំនៅនោះឋិតថេរយូរទៅបាន, បើបណ្តោយឲ្យបាក់បែកលេចធ្លុះធ្លាយរហែករហោក ឬឲ្យស្រុតផ្អៀងទេទ្រេតទេទ្រោត មិនថែជួសជុលទល់ទ្រទេ នឹងបណ្តាលទៅជាមន្ទិលគឺទ្រុឌទ្រោមខូចវិនាសអន្តរធាន ខានបានជ្រកអាស្រ័យនៅតទៅ ។

សេចក្តីខ្ជិលជាមន្ទិលរបស់សម្បុរ = ការសំអាតជំរះរាងកាយ ជាគុណធម៌ឲ្យកើតបរិសុទ្ធរាងកាយ ។ សេចក្តីខ្ជិលច្រអូស មិនឧស្សាហ៍លាងជំរះរាងកាយ ដែលប្រឡាក់ប្រឡូសដោយមន្ទិលគឺធូលីក្អែលក្អកឬ

ការបែកញើសហូរចេញមកអាប់អួរធុំក្លិនអាក្រក់ ដោយទឹកនឹងគ្រឿង លុបលាងទេ នឹងនាំឲ្យទៅជាមន្ទិលសៅហ្មងគឺមានសម្បុរកាយអាក្រក់ បណ្ដាលទៅជារោគផ្សេងៗ មានឫសបមកមរមាស់ជាដើម ពុំនោះសោត គ្រឿងឧបភោគបរិភោគ ដែលប្រឡាក់ប្រឡូសដោយញើសក្អែលអាប់អួរ មិនបានស្ងោរបោក គក់ជ្រលក់លាងហាលឬបោសជូតសំអាតធ្វើឲ្យស្អាតបាតទេ ជាហេតុនាំឲ្យទៅជាមន្ទិលសៅហ្មង គឺមានពណ៌សម្បុរអន់អាប់ អាក្រក់ ធុំក្លិនអសោចិ៍បើប្រើប្រាស់មិនកើត មិនគួរដល់ការងារឡើយ ។

សេចក្ដីធ្វេសប្រហែសជាមន្ទិលរបស់អ្នករក្សាទ្រព្យ=ការរកំងប្រយ័ត្ន ជាគុណក្នុងការរក្សាទ្រព្យសម្បត្តិឬសីល ដូចបុរាណលោកថាប្រហែសបាត់ប្រយ័ត្នគង់ៗ សេចក្ដីធ្វេសប្រហែសព្រងើយកន្តើយនៃគ្រហស្ថរវល់តែដេកឬរវល់តែនឹងលេងឥតប្រយោជន៍ មិនថែទាំប្រុងប្រយ័ត្នទ្រព្យសម្បត្តិ បណ្ដោយទៅតាមសភាវការងារ សម្បត្តិទាំងនោះ នឹងវិនាសអន្តរាយដោយប្រការផ្សេងៗជាមិនខាន, សេចក្ដីធ្វេសប្រហែសឬការមិនប្រុងប្រយ័ត្នគ្រប់គ្រងរក្សាសង្រួមនូវទ្វារទាំង ៦ មានចក្ខុទ្វារជាដើមនៃបព្វជិត ជាហេតុបើកឱកាសឲ្យដល់ពួកសត្រូវ គឺកិលេសមានរាគៈជាដើមចូលមកញាំញីគ្របសង្កត់បង្ខិលចិត្តនៃបព្វជិតនោះ ឲ្យហ៊ានប្រព្រឹត្តធ្វើនូវអំពើអាក្រក់ផ្សេងៗមានគរុកាបត្តិជាដើម ដែលជាអំពើមិនសមគួរដល់សមណភេទ ការមិនប្រុងប្រយ័ត្ននេះឯងជាមន្ទិលនាំឲ្យខូចខាតទ្រព្យសម្បត្តិឬសីល ។

ការប្រព្រឹត្តអាក្រក់ជាមន្ទិលរបស់ស្ត្រី = ការមិនប្រព្រឹត្តកន្លងប្រពៃណីជាសេចក្តីបរិសុទ្ធនៃស្ត្រីទាំងឡាយ ។ ការប្រព្រឹត្តខុសគន្លងប្រពៃណី ឈ្មោះថាជាមន្ទិលលាមកអាក្រក់បំផុតរបស់ស្ត្រី ។ អំពើជាមន្ទិលនេះ មានទោសច្រើនប្រការ មានការអន្តរាយទ្រព្យសម្បត្តិទាស់ទែងលែងលះប្តីប្រពន្ធ ឬត្រូវគេបណ្តេញចេញចាកត្រកូលរបស់ខ្លួន, បណ្តាលឲ្យកើតវិប្បដិសារៈជាមន្ទិលនាំឲ្យដល់នូវសេចក្តីទុក្ខលំបាកគ្រប់យ៉ាង ។

សេចក្តីកំណាញ់ជាមន្ទិលរបស់អ្នកឲ្យ = ចាគចេតនា ជាគុណជាតិប្រសើរវិសេស អាចញុំាងចិត្តឲ្យជ្រះថ្លា នឹកដល់ការបរិច្ចាគកាលណា ក៏មានបីតិកើតក្នុងកាលនោះ ព្រោះនឹកឃើញថា អាត្មាអញបានបំពេញកុសល បានធ្វើល្អហើយ, មាតាបិតា សមណព្រាហ្មណ៍ ស្មូមយាចក អាត្មាអញបានទំនុកបម្រុងចិញ្ចឹមហើយ ។ សេចក្តីកំណាញ់ កកាញ់ទ្រព្យសម្បត្តិទុក ឲ្យគ្រាន់តែបានឈ្មោះថាជាសេដ្ឋី មិនបានចែកចាយទ្រព្យសម្បត្តិជាទានសាធារណប្រយោជន៍ ឬមិនបរិភោគខ្លួនឯង ជាមន្ទិលនាំឲ្យសៅហ្មងចិត្ត ។ បើគិតថា "មានច្រើន" គេគួរពេញចិត្ត តែបើនឹកថាអាត្មាអញបានធ្វើប្រយោជន៍អ្វីខ្លះហើយឬ? ក៏អន់ចិត្តខ្លួនឯង ព្រោះនឹកឃើញថា មាតាបិតា សមណព្រាហ្មណ៍ ស្មូមយាចក អាត្មាអញមិនដែលបានចិញ្ចឹមទំនុកបំរុងសោះ ដល់មរណ-

កាលមកដល់ មិនមានអ្វីជាទីពឹង មានតែមន្ទិលគឺចិត្តទោមនស្សក្តៅក្រហាយស្តាយក្រោយ ៗ

បាបធម៌ទាំងឡាយជាមន្ទិលក្នុងលោកនេះផងក្នុងលោកខាងមុខផង= កុសលធម៌ ជាធម៌នាំឲ្យកើតសេចក្តីសុខ – បំរើនទៅនាលោកនេះនឹងបរលោក ៗ បាបធម៌ដែលមកកើតពីការប្រព្រឹត្តិអាក្រក់ដោយកាយវាចាចិត្ត, លោករាប់បញ្ចូលក្នុងអកុសលកម្មបថទាំង ១០ ឬក្នុងឧបក្កិលេសទាំង ១៦ មានអភិជ្ឈាវិសមលោភៈជាដើម នេះជាមន្ទិលនាំឲ្យសៅហ្មង កើតទុក្ខទោសអន្តរាយ ៗ ធម្មជាតិអំពើអាក្រក់ ដែលបុគ្គលធ្វើហើយ កុំថាឡើយដល់អំពើធំៗ សូម្បីតែអំពើតូចៗ ក៏ជាមន្ទិល ហើយមិនមែនក៏បាំងបាត់ស្ងាត់ដែរ បើទុកជាកំបាំងបាត់ក្នុងលោកនេះ ទៅលោកខាងមុខគង់តែឃើញជាក់ស្តែងដោយខ្លួនឯងមិនខាន ជួនកាលក៏ឃើញជាក់ស្តែងក្នុងលោកនេះ លុះទៅកាន់លោកខាងមុខក៏ឃើញជាក់ស្តែងទៀត ៗ

អវិជ្ជាជាមន្ទិលដ៏ក្រៃលែងជាងមន្ទិលទាំងនោះទៅទៀត = ពន្លឺកើតឡើងងងឹតបាត់ទៅ វិជ្ជាកើតឡើង អវិជ្ជារលត់បាត់ទៅ, ហេតុនេះ វិជ្ជាជាគុណធម៌ខ្ពង់ខ្ពស់បំផុត ៗ អវិជ្ជាគឺការងងឹតល្ងង់ វង្វេងក័ន្តប្រឡំ មិនចេះមិនដឹង, ជាមេដើមអាទិ៍ដើមបម ធ្វើមនុស្សសត្វឲ្យល្ងង់វង្វេងក័ន្តគំនិតមិនយល់សេចក្តីពិតមែន ៗ តាមបរមត្ថលោកពោលថា មិនដឹងមិនយល់ក្នុងហេតុ ៨ យ៉ាង មានមិនដឹងថា « នេះជាទុក្ខ, នេះជាហេតុនាំឲ្យកើត

ទុក្ខ, នេះជាឧបាយនាំឲ្យរលត់ទុក្ខ, នេះបដិបទាដំណើរនាំឲ្យដល់នូវសេចក្ដីរលត់ទុក្ខជាដើម» ។ មន្ទិលដទៃ គេអាចនឹងកំចាត់បង់បានដោយស្រួល ព្រោះអាចមើលឃើញចាប់បានសង្កេតយល់, ដូចមន្តទាំងឡាយកាលយើងខំឧស្សាហ៍ស្វាធ្យាយហើយក៏នឹងមិនបាត់បង់ទៅណាទេ យើងអាចយកមកប្រើប្រាស់គ្រប់ពេលបាន, ចំណែកអវិជ្ជាវិញជាធម៌ល្អិតជិតជាប់នៅក្នុងសន្ដាន កម្រនឹងដំរះឲ្យស្អាតណាស់ មិនមានសភាវៈអ្វីយកទៅលុបលាងឲ្យស្អាតបាតបានឡើយ មានតែវិជ្ជាមួយប៉ុណ្ណោះជាពន្លឺយកទៅបន្សាត់បង់បាន ហេតុនេះបានជាព្រះបរមសាស្ដាទ្រង់ត្រាស់ថា: អវិជ្ជាជាមន្ទិលក្រៃលែងជាងមន្ទិលទាំងអស់ ។

ព្រះគ្រូសិរីសោភ័ណ កិម - គួរ

បណ្ដារបស់ដែលកើតឡើង វិជ្ជាជាធម្មជាតិថ្កើងប្រសើរ បណ្ដារបស់ដែលលិចចុះទៅ សេចក្ដីល្ងង់ជាធម្មជាតិប្រសើរ បណ្ដាសត្វដើរទៅដោយជើង ព្រះសង្ឃលោកជាបុគ្គលប្រសើរ បណ្ដាអ្នកចេះនិយាយពីរោះ ព្រះសម្ពុទ្ធជាម្ចាស់ព្រះអង្គប្រសើរ ។ វុដ្ឋិសូត្រ ។

បណ្ដាពួកសត្វទ្វេបាទ ព្រះសម្ពុទ្ធជាម្ចាស់ព្រះអង្គប្រសើរបំផុត បណ្ដាពួកសត្វចតុប្បាទ សត្វអាជានេយ្យជាសត្វប្រសើរបំផុត បណ្ដាភរិយា ប្រពន្ធជឿស្ដាប់តាមពាក្យជាស្រីប្រសើរបំផុត បណ្ដាបុត្រកូនដែលប្រដៅងាយ ជាអ្នកប្រសើរបំផុត ។ ខត្តិយសូត្រ ។

# មគ្គមួយ ឬ មគ្គប្រាំបី?

យើងជាពុទ្ធបរិស័ទគួរពិចារណារឿងសំខាន់មួយ គឺចំនួនរបស់មគ្គជាផ្លូវទៅព្រះនិព្វាន ឲ្យឃើញថា មគ្គនោះមានមួយ ឬ មានប្រាំបី? ។ យើងធ្លាប់បានឮរឿយ ៗ មកហើយថា "មគ្គប្រាំបី ឬ ផ្លូវប្រាំបី" ជាផ្លូវទៅព្រះនិព្វាន ។ ពាក្យនេះធ្វើអ្នកស្ដាប់ឲ្យស្ដាប់បានថា "ផ្លូវទៅព្រះនិព្វានមានដល់ប្រាំបី, មិនមែនតែមួយ" ជាពាក្យបណ្ដុះសេចក្ដីចូលចិត្តខុស ឬ សេចក្ដីចូលចិត្តត្រូវ ដល់អ្នកស្ដាប់? ។ បញ្ហានេះសូមអស់លោកអ្នកជួយពិចារណា!

បើយើងពិចារណាតាមគោលនៃការពិសោធន៍ ៥ ប្រការ ដូចមានខាងមុខនេះ នឹងឃើញជាក់ថា ពាក្យថាមគ្គប្រាំបី ឬ ផ្លូវប្រាំបី នោះខុស:

១) មានបាលីថា "អដ្ឋង្គិកោ មគ្គោ មគ្គឬផ្លូវប្រកបដោយអង្គប្រាំបី" គឺត្រូវព្រមដោយអង្គ (អវយវៈ) ប្រាំបី ទើបពេញជាមគ្គ ឬជាផ្លូវទៅបាន ។ ការធ្វើនំ លុះតែប្រកបព្រមដោយម្សៅ ស្ករ ស៊ុត ទឹក ។ល។ ទើបកើតជានំបាន យ៉ាងណាមិញ? មគ្គក៏យ៉ាងនោះ, បើញែកគ្នា ក៏មិនបានសម្រេចជាមគ្គឡើយ, បានត្រឹមតែជាអង្គរបស់មគ្គប៉ុណ្ណោះ; ដូចគ្នានឹងអង្គរបស់នំកាលដែលនៅជាម្សៅ ឬស្ករ ។ល។ នៅឡើយនោះ គេពុំទាន់ហៅថានំទេ, យើងនឹងហៅអង្គរបស់មគ្គថាជា "មគ្គ" ពុំទាន់បាន ដូចគ្នានឹងហៅម្សៅ ថានំពុំទាន់បានដូច្នោះ ។ នេះផ្ដុះសេចក្ដីឲ្យឃើញច្បាស់ថា ពាក្យថាមគ្គ ឬផ្លូវប្រាំបីនោះខុស ។

២) មនុស្សម្នាក់នឹងដើរផ្លូវប្រាំបី ក្នុងពេលមួយជាមួយគ្នាតែម្ដងដូចម្ដេចបាន ? ។ បើប្រសិនជាសន្មតថា មានផ្លូវប្រាំបីខ្សែតាំងខាងដើមខាងចុង រហូតទៅ ហើយមួយ ៗ សុទ្ធតែជាផ្លូវទៅព្រះនិព្វានបានដូចគ្នាទាំងអស់ នោះមនុស្សម្នាក់ ៗ មិនបាច់ដើរគ្រប់ទាំងប្រាំបីផ្លូវទេ ដើរតែផ្លូវណាមួយក៏បានដល់ទៅព្រះនិព្វានហើយ, ប៉ុន្តែបើប្រសិនជាសន្មតថាមានផ្លូវញែកចេញជាប្រាំបីផ្លូវនោះ ក៏ទីដែលត្រូវទៅគឺព្រះនិព្វាននោះមិនទៅជាមានថ្នាក់ទាបខ្ពស់ខុសគ្នាដល់ទៅប្រាំបីឋានទៅហើយឬ ? បើប្រសិនជាសន្មតថាមានផ្លូវញែកជាប្រាំបីខ្សែតែខាងដើម ដល់ទៅខាងចុងរួមចូលគ្នាជាមួយខ្សែវិញ ដូច្នោះក្នុងមនុស្សម្នាក់ ៗ នឹងត្រូវដើរសារចុះសារឡើងឲ្យគ្រប់ផ្លូវទាំងប្រាំបីខ្សែពីខាងដើម ហើយដល់ខាងចុងទើបចូលទៅដើររួមគ្នាតែមួយខ្សែ, បែបនេះក៏ហួសវិស័យនឹងដើរបាន ។ នេះក៏ដុះសេចក្ដីឲ្យឃើញជាក់ថា ពាក្យថាមគ្គ ឬផ្លូវប្រាំបីនោះខុស ។

៣) មានបាលីថា “ឯកាយនោ ភិក្ខវេ មគ្គោ ម្នាលភិក្ខុទាំងឡាយ ! ផ្លូវជាគ្រឿងទៅនៃមនុស្សម្នាក់...” គឺផ្លូវទៅព្រះនិព្វានមានតែមួយ មិនមែនមានដល់ប្រាំបីទេ ពីព្រោះនឹងបែងភាគមនុស្សអ្នកត្រូវទៅព្រះនិព្វាននោះ ក្នុងម្នាក់ៗជាប្រាំបីចំណែកឲ្យដើរគ្រប់ទាំងប្រាំបីផ្លូវព្រមគ្នាក្នុងគ្រាមួយពុំបានឡើយ ។ ការប្រតិបត្តិដើម្បីទៅកាន់ព្រះនិព្វានមានច្រើនរយៈច្រើនពាន់អាការ កិរិយាធ្វើក៏ផ្សេង ៗ គ្នា តែដល់បាន

សម្រេចផលដូចគ្នា, មនុស្សខ្វះបានទៅដល់ព្រះនិព្វានដោយអាការនេះ មនុស្សខ្វះបានទៅដល់ព្រះនិព្វានដោយអាការនោះ; ហេតុនេះបានជាព្រះសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់ត្រាស់ថា "ផ្លូវជាគ្រឿងទៅនៃមនុស្សម្នាក់" ។ នេះក៏ធ្លុះសេចក្ដីឲ្យឃើញជាក់ថា ពាក្យថាមគ្គ ឬផ្លូវប្រាំបីនោះខុស ។

៤) បើនឹងឲ្យអង្គមគ្គមួយៗ ជាផ្លូវមួយក៏ស្មើរតែបានដែរ តែអង្គមួយនឹងទៅព្រះនិព្វានពុំបានឡើយ, បំពោះអង្គមួយ ដែលយើងឃើញបានងាយ ដូចយើងប្រតិបត្តិតាមអង្គគឺសម្មាវាចា (សំដីត្រូវ) តែមួយយ៉ាងប៉ុណ្ណោះ នឹងទៅដល់ព្រះនិព្វានដូចម្ដេចបាន? ។ បើនឹងយកផ្លូវប្រាំបីខ្សែមកតគ្នាជាតំណៗ ឲ្យទៅជាផ្លូវតែមួយជាមួយគ្នា ដូច្នោះក៏មិនមាននរណាហៅថាផ្លូវប្រាំបី គេនឹងហៅថាផ្លូវប្រាំបីថ្នាក់ ឬប្រាំបីរយៈ ។ នេះក៏ធ្លុះសេចក្ដីឲ្យឃើញជាក់ថា ពាក្យថាមគ្គ ឬផ្លូវប្រាំបីនោះខុស ។

៥) បើនឹងយកផ្លូវប្រាំបីខ្សែមកតគ្នាជាប្រាំបីថ្នាក់ ឬប្រាំបីរយៈក៏នឹងជាមគ្គតាមដែលត្រូវការនេះពុំបាន ព្រោះអង្គមួយ ៗ មិនមែនជាផ្លូវមួយថ្នាក់ ឬមួយរយៈ ដូច្នោះទេ ។ មគ្គគឺការប្រតិបត្តិដែលនឹងត្រូវធ្វើឲ្យព្រមព្រៀងគ្នាទៅទាំងប្រាំបីអង្គដូចខ្សែប្រាំបីធ្លុង ដែលហៅតាមភាសាពុទ្ធសាសនាថា "ធម្មសាមគ្គី" ទើបនឹងសម្រេចជាផ្លូវគឺមជ្ឈិមាបដិបទាបាន ។ ហេតុនេះ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា "ផ្លូវប្រកបដោយអង្គប្រាំបី" មិនមែនត្រាស់ថា "ផ្លូវប្រាំបី" ទេ ។ នេះក៏ធ្លុះសេចក្ដីឲ្យឃើញច្បាស់ថា ពាក្យថាមគ្គ ឬផ្លូវប្រាំបីនោះខុសស្រឡះ ។

ពាក្យប្រាប់ថា មគ្គ ឬផ្លូវប្រាំបី ធ្វើឲ្យកើតផលមិនល្អ ដល់អ្នកស្តាប់ គឺឲ្យខូចសទ្ធា ឲ្យសង្ស័យមមាំក្នុងចិត្តថា បណ្តាផ្លូវទាំងប្រាំបី, ខ្លួនម្នាក់ៗ អាចដើរផ្លូវណាមួយក៏បាន; ម្ល៉ោះហើយទើងជ្រើសយកតែផ្លូវមួយៗ តាមចិត្តស្ម័គ្រ ដែលក្នុងទីបំផុតនឹងដល់ទីរលត់ទុក្ខពុំបានឡើយ ។ មួយទៀត ពាក្យនេះ មុនដំបូងធ្វើអ្នកស្តាប់ឲ្យអស់គំនិតបញ្ញា ខាងក្រោយធ្វើឲ្យត្រូវអវិជ្ជារួបរឹតកាន់តែច្រើនថែមឡើងទៀតលើសដើម, រួមទាំងមុនទាំងក្រោយ ជាពាក្យទម្លាយសទ្ធាល្អ ហើយបណ្តុះសទ្ធាមិនល្អ គឺសេចក្តីចូលចិត្តខុសឲ្យកើតឡើងដល់អ្នកស្តាប់ ។ គួរសង្វេគណាស់ បើយើងបណ្តោយឲ្យបងប្អូនរួមពុទ្ធសាសនាសំគាល់យកពាក្យខុសនេះ ទុកនៅក្នុងសន្តានតទៅមុខដោយទុកចិត្តថាត្រូវហើយ ក៏ប្រតិបត្តិតាមខុសនោះទៅ ។ កាលបើបុសគល់គឺសទ្ធាពុកផុយរលួយខូចអស់ទៅហើយ ដើមដងផ្លែផ្កានឹងចម្រើនដូចម្តេចបាន? ។ យើងគួរជម្រះវាចាដែលនាំឲ្យអ្នកសិក្សាតិចឬក្មេងតូច ៗ ស្តាប់ហើយឧបលទ្ធិខុសទុកដូច្នេះចេញ, កុំបណ្តោយឲ្យផុះលូតលាស់គ្របសន្តានចិត្តពុទ្ធបរិស័ទ ដូចស្មៅឬកូនឈើដុះគ្របផ្លូវបន្តិចម្តងៗ ដរាបដល់ជិតនោះឡើយ ។

បើដូច្នេះ យើងត្រូវប្រាប់អ្នកស្តាប់ថា “មគ្គមួយ” ឬ “មគ្គមានអង្គប្រាំបី” គឺមានផ្លូវវែងមួយខ្សែ ប្រកបដោយអង្គឬលក្ខណៈប្រាំបី ជាផ្លូវទៅព្រះនិព្វាន, ប្រៀបដូចផ្លូវដីវែងមួយខ្សែជាផ្លូវដើរ

ដើររហូតទៅដល់ទីបំផុតលោក ។ ផ្លូវនោះដែលនឹងឲ្យសម្រេចប្រ-
យោជន៍ដល់អ្នកដំណើរទៅបាន លុះតែប្រកបដោយអង្គប្រាំបី គឺ

១ – មានផែនទី ឬ ពាក្យពន្យល់អ្នកដំណើរ

២ – មានរបៀបត្រឹមត្រូវគាប់ឲ្យអ្នកដំណើរសង្កេតផ្លូវបាន

៣ – មានទឹកបរិភោគតាមរយៈ

៤ – មានអាហារបរិភោគតាមរយៈ

៥ – មានផ្ទះសំណាក់តាមរយៈ

៦ – មានមន្ទីរព្យាបាលរោគតាមរយៈ

៧ – មិននៅក្រោមអំណាចសត្វសាហាវនឹងចោរ

៨ – ស្រួលល្អដើរទៅបានរហូត

សេចក្ដីនេះយ៉ាងណា ? ផ្លូវដែលត្រូវដើរដោយចិត្តទៅព្រះនិព្វានក៏
យ៉ាងនោះ គឺលុះតែប្រកបដោយអង្គប្រាំបី គឺ

១- សេចក្ដីយល់ត្រូវក្នុងការប្រតិបត្តិផ្លូវដំណើរទៅ ហៅថា សម្មាទិដ្ឋិ

២ – តម្រិះត្រូវក្នុងចន្លោះផ្លូវ ហៅថា សម្មាសង្កប្បោ

៣ – ការនិយាយត្រូវក្នុងចន្លោះផ្លូវ ហៅថា សម្មាវាចា

៤ – ការងារត្រូវក្នុងចន្លោះផ្លូវ ហៅថា សម្មាកម្មន្តោ

៥ – ស្វែងរកស្បៀងដ៏ប្រពៃក្នុងចន្លោះផ្លូវ ហៅថា សម្មាអាជីវោ

៦ – ព្យាយាមត្រូវក្នុងខណៈដើរផ្លូវ ហៅថា សម្មាវាយាមោ

៧ – បញ្ជូនចិត្តឲ្យរលឹកដល់វត្ថុដ៏ប្រពៃ ហៅថា សម្មាសតិ

៨ – ដំកល់ចិត្តឲ្យនឹងយ៉ាងខ្ជាប់ខ្ជួន ហៅថា សម្មាសមាធិ

ដូច្នេះទើបបានទៅដល់ឋានដែលខ្លួនប្រាថ្នា គឺព្រះនិព្វាន ។

ផ្លូវថ្នល់សម្រាប់ដើរដោយជើងឬកាយ ប្រៀបធៀបទៅនឹងផ្លូវដែលត្រូវដើរដោយការប្រតិបត្តិផ្លូវចិត្ត មានសេចក្ដីដូចពណ៌នាមកនេះ ។

ការប្រាប់ត្រូវដូច្នេះ ឲ្យកើតផលដល់អ្នកស្ដាប់ផ្ទុយគ្នានឹងការប្រាប់ខុសខាងដើម គឺឲ្យអ្នកស្ដាប់ចូលចិត្តត្រូវ យល់បានខ្លួនឯង ជឿសមត្ថភាពរបស់ខ្លួន ជាសត្វាដ៏មាំមួនអាចផ្ញើនិស្ស័យនៃព្រះនិព្វានឲ្យមានដំណើរប្រព្រឹត្តទៅបានដោយស្រួល, ប្រៀបដូចការរៀបឥដ្ឋធ្វើផ្ទះ ឬប្រាសាទ កាលបើគេបុកឫសខាងក្រោមមាំមួនហើយ, គ្រាងខាងលើសន្សឹម ៗ កឡើងទៅតាមលំដាប់ ដរាបដល់បានសម្រេចដោយប្រពៃ ។

សូមលោកអ្នកអានបានចម្រើន !!!

ចាប ពិន

ការប្រុងប្រយ័ត្ន ជាផ្លូវនៃសេចក្ដីរស់នៅ

ការប្រហែសធ្វេស ជាផ្លូវនៃសេចក្ដីស្លាប់ ។

ធម្មបទ

# អក្សរសាស្ត្រជាពន្លឺជាតិ ជាគោលចារឹកជាតិ
# អក្សរសាស្ត្ររលត់ ជាតិរលត់ ។

## ប្រវត្តិអ្នកព្រះភិរម្យភាសាអ៊ូ ហៅង៉ុយ

ឈ្មោះ អ៊ុក-អ៊ូ ជាកូនទី ២ នៃចៅពញាធម្មាភ ម៉ុក-អ៊ុក និងអ្នកស្រី អៀង ដែលជាពូជអំបូរបុរោហិត កើតនៅភូមិបន្ទាយ ឃុំកំបូល ខែត្រកណ្ដាល ស្រុកក្នុំពេញក្នុងរាំង ព. ស. ២៤០២ ត្រូវជាចៅរបស់ពញាម៉ុក ដែលជាអ្នកប្រាជ្ញម្នាក់ធ្វើជាមន្ត្រីក្នុងព្រះបរមរាជវាំង ពញាម៉ុកជាបុត្រម្ចាស់អង្គម៉ុក ។ ឈ្មោះ អ៊ុក-អ៊ូ បានបួសជាសាមណេរ ៣ វស្សា ជាភិក្ខុ ៣ វស្សា រៀនព្រះត្រៃបិដកចប់គម្ពីរធម្មបទ ។

ម៉ុក-អ៊ុក ធ្វើជាមេឃុំកំបូល ឈ្មោះ អ៊ុក-អ៊ូ បានជួយធ្វើការជាក្រមផងជាស្មៀនផង ជាអ្នកមានវោហារលែបខាយ ប្រាជ្ញាវាងវៃ ចេះចាំរៀងព្រេងព្រឹទ្ធ គតិលោកគតិធម៌ជាច្រើន ចេះច្រៀងចេះភ្លេងខ្មែរភ្លេងសៀមជាច្រើនបទ ។

ពេលស្រុកក័ន្ដប្រែ ឈ្មោះ អ៊ុក-អ៊ូ ឈប់ធ្វើការ ដើរច្រៀងដេញខ្សែដៀវយ៉ាងចំណាន កំសាន្តចិត្តអ្នកស្រុក រហូតដល់មានកិត្តិ-សព្ទ ល្បីខ្ចរខ្ចាយផ្សាយដល់ព្រះរាជដំណាក់ព្រះបាទសម្ដេចព្រះនរោត្តម ព្រះករុណាសព្វព្រះរាជហឫទ័យ បានឲ្យហៅឈ្មោះអ៊ូមកច្រៀងថ្វាយ ។

លេខកូត : ...............
លេខបញ្ជី : ..........១០៣

លុះដល់មករជ្ជកាលព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ឈ្មោះអ៊ូ បានចូលក្នុងក្រុមភ្លេងព្រះបរមរាជវាំង ទទួលងារជាព្រះភិរម្យភាសា អ៊ូ តែព្រះករុណាទ្រង់ត្រាស់ឲ្យហៅថា ង៉ុយ វិញ កុំឲ្យច្រឡំនឹងឈ្មោះនាយក្រុមវាំងម្នាក់ ដែលមានឈ្មោះថា អ៊ុក អ៊ូ ដែរ ទើបជាប់ឈ្មោះង៉ុយ ជាប់ដរាបមក ។

ឆ្នាំមួយ ព្រះអង្គម្ចាស់សៀមក្រុមព្រះទំរង់រាជានុភាព នឹងលោកស៊ីដែសជាតិបារាំង បានចូលមកគាល់ព្រះករុណា ប្រទេសកម្ពុជាយើង កាលណោះមានប្រគំភ្លេងផ្សំបំរើងទទួល អ្នកព្រះភិរម្យភាសាង៉ុយឈ្នះគេ ខាងខ្សែដៀវបានរង្វាន់ជាច្រើន ។ កិត្តិសព្ទព្រះភិរម្យភាសាបានផ្សាយដល់ស្រុកសៀម មានព្រះរាជសារពីស្រុកនោះ មកសុំលោកទៅច្រៀងថ្វាយស្តេចសៀម ព្រះភិរម្យភាសាង៉ុយបានអនុញ្ញាតទៅក្រុងបាង-កកតាមសេចក្តីសុំ ច្រៀងនៅក្រុងនោះរវាង៣ខែ បានទទួលសេចក្តីរាប់អានទាំងក្សត្រទាំងមន្ត្រី ។ ព្រះចៅសៀមបានប្រទានងារជាព្រះភិរម្យភាសា "ផៃពេ៉ាះលៀកឹង" ទ្រង់ប្រទានខ្សែរប្រាក់ខ្លង់ដ៏មានក្បាច់យ៉ាងល្អ ព្រមទាំងប្រាក់នឹងវត្ថុផ្សេងៗ ជាច្រើន ។

ព្រះភិរម្យភាសាង៉ុយបានបញ្ចេញប្រាជ្ញរបស់លោកឲ្យឃើញច្បាស់ កាលច្រៀងតនឹងភិរម្យយូ នៅខែត្របាត់ដំបង បានរង្វាន់ ៥០០ រៀល នឹងសេះល្អមួយ ដែលជារង្វាន់លោករ៉េស៊ីដង់ខេត្តនោះ ។ ទំនុកច្រៀងកាលជាន់នោះចាំពុំបានសព្វគ្រប់ទេ តែមានសេចក្តីដូចតទៅនេះ

កិរម្យគាសាយូសួរថា "ភ្នំព្រះសុមេរុនៅទីណា? កំពស់ប៉ុន្មានយោជន៍? ជុំវិញប៉ុន្មានយោជន៍? នៅជើងភ្នំមានដើមឈើអ្វីខ្លះ?"

កិរម្យគាសាន៊ុយឆ្លើយថា "ឲ្យខ្ញុំប្រាប់ត្រង់ ឬឲ្យខ្ញុំកុហក, បើទុកជាត្រង់ ឬ កុហកក៏គង់តែបញ្ជាស់ដែរ"

ក-យ. — ចូរអ្នកប្រាប់ឲ្យត្រង់

ក-ន. — ខ្ញុំព្រមចាញ់ឥតប្រកែកទេ ព្រោះមិនដែលទៅដល់ភ្នំព្រះសុមេរុសោះ ៗ សុំសួរវិញថា តាមផ្លូវកប៉ាល់ពីបាត់ដំបងទៅទន្លេសាបតើប៉ុន្មានគីឡូ? ពីទន្លេសាបទៅភ្នំពេញតើប៉ុន្មានគីឡូ? ទន្លេសាបមានជម្រៅប៉ុន្មានម៉ែត្រ? តាមផ្លូវថ្នល់ពីបាត់ដំបងទៅភ្នំពេញតើប៉ុន្មានគីឡូ?

កិរម្យគាសាយូឆ្លើយមិនរួច ត្រូវអ្នកកិរម្យគាសាន៊ុយបន្តុះបង្អាប់ទាល់តែចុះចាញ់ ដោយមិនចេះផែនទីស្រុករបស់ខ្លួន ៗ

ក្រៅពីចម្រៀងខ្សែដៀវ អ្នកព្រះកិរម្យគាសាន៊ុយ ជាអ្នកពេញចិត្តកង់អក្សរសាស្ត្ររបស់ជាតិ បានតែងច្បាប់ជាពាក្យកាព្យជាច្រើន ជាបទពាក្យ ៧ ខ្លះ ជាបទកាកគតិខ្លះ គឺច្បាប់ល្បើកថ្មី កេរ្តិ៍កាលថ្មី ធម៌ថ្មីធម៌ចាស់ រំលឹកជាសកៀនជាតិខ្មែរ ប្រវត្តិអំពីការប្រែប្រួលស្រុកទេសកតញ្ញូ កតវេទី ត្រៃលក្ខណ៍ ចម្រៀងតស្រីប្រុស, ច្បាប់ ៤ ខាងដើមពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយហើយ ៗ

អ្នកព្រះគិរម្យគាសា នុ៉យ មានភរិយាឈ្មោះនាងអ៊ិន បានកូន ៦ នាក់ គឺកូនទី ១ ឈ្មោះដួង ទី ២ ឈ្មោះចេង ទី ៣ ឈ្មោះតាម ទី ៤ ឈ្មោះចិន ទី ៥ ឈ្មោះប៊ុង ទី ៦ ឈ្មោះចៅ ៗ លោកអនិច្ចកម្មដោយជរា ក្នុងខែមិគសិរ ថ្ងៃសុក្រ ៧ កើត ព.ស. ២៤៧៩ ក្នុងរវាងអាយុ ៧២ ឆ្នាំ ៗ

អ្នករៀបរៀង អាចារ្យ គ៊ុ - ប៊ុង ជាកូន

មួយកើតអស្សុជសម្លាប់មាន់ ចំអិនគ្រប់គ្រាន់ជួសជាក់ចាន
រៀបសែនព្រះភូមិតាមបុរាណ ថាខានខុសក្បួនប្រវេណី ៗ
ហ្នឹងហៅចាស់ឆោតនាំក្មេងព្រើល ហែកមាត់មាន់មើលចង្កាពីរ
អាដែងព្រះភូមិមានឈ្មោលញី ថាសែនរកស៊ីបានផលស្រូវ ៗ
មានជូនជូនតាទៅស្រុកប្រែត បណ្ដែតសំប៉ានប្រានសំពៅ
សំពះអារក្សផ្លូវខាងឪ ខាងម៉ែក៏ត្រូវមិនសូវខុស ៗ
ថ្វាយបេកថ្វាយស្រាជារង្វាន់ ខ្មោចចូលជិះជាន់រូបស្រីប្រុស
កូនចៅអើយជឿព្ទដីតាចុះ រូបស្លាប់ពីព្រោះតែផលកម្ម ៗ
រូបសុខដោយសារតែផលបុណ្យ កាលពីជាតិមុនខ្ជាប់សីលប្រាំ
ជាតិនេះអាយុអង្វែងឆ្នាំ កូនចៅអ្នកចាំជឿឲ្យជាក់ ៗ

អ្នកព្រះគិរម្យគាសា អ៊ុ ហៅ នុ៉យ

១ – **ប្រស្នាជីវិត**.– ព្រៃព្រឹក្សាលតាជាតិតែងមានលំអប្លែកៗ តាមរដូវ ប្រកបដោយស្លឹកខៀវខ្ចីស្រស់ស្រគាត់ ដេរដាសដោយផ្ការីក ស្គុះស្គាយ ពេលក្លិនកាយអប់អាកាសក្រអូបល្ហួងល្ហើយ បក្សាបក្សី តែងប្រកាសលំអស្រែកយំរងំពិរោះ នេះជាទស្សនភាពដែលយើងចូលចិត្តគយគន់ៗ យើងពេញចិត្តធម្មជាតិបែបនោះយ៉ាងណា យើងក៏ប្រាថ្នាឲ្យជីវិតរបស់យើងដើរទៅកាន់សេចក្តីរុងរោចន៍យ៉ាងនោះដែរ ហើយ យើងតែងរាសង្ឃឹមនោគតិនៃអនាគតរបស់យើងតាមភាពនោះៗ

តាមសេចក្តីពិត, ជីវិតប្រព្រឹត្តទៅរៀងរាល់ថ្ងៃ តែងជួបប្រទះនូវឧបសគ្គ ជាអនេកប្បការស្ទើរគ្រប់ជំហាន ទើបការកសាងជីវិត កើតជាប្រស្នាប្រចាំលោកទូទៅ ៗ

២ – **ការអាងប្រាសចាកហេតុផល**.– យើងធ្លាប់បានឮជារឿយៗមកហើយ ចំពោះពាក្យដោះស្រាយចំណោទនេះ គេច្រើនបណ្តាយថា "បើរកប្រឹងទីងដុះចាំបាច់អ៊ុំទឹងស្រោចទឹក" ឬថា "ធ្វើម្តេចសំណាងយើងគ្មាន ទុកជាខំប្រឹងយ៉ាងណាក៏មិនលូតលាស់នឹងគេដែរ" ពុំនោះក៏ផ្តេកវេរក្តីអភ័ព្វរបស់ខ្លួនទៅលើការមើលចំណាំនៃទេព្តា ឬខ្មោចអារក្ស ខ្លះក៏ប្រគល់ខ្លួនទៅលើជោគជតារាសី ឬផ្កាយនព្វគ្រោះ ជឿថា

អំណាចស័ក្តិសិទ្ធិទាំងនោះ បានគ្រប់គ្រងជីវិតរបស់ខ្លួនយ៉ាងណាហើយ ជីវិតនឹងប្រព្រឹត្តទៅយ៉ាងនោះឥតផ្លូវកែប្រែបានឡើយ ។

ជំនឿបែបនោះនាំឲ្យមនុស្សលះបង់សេចក្តីប្រឹងប្រែង បណ្តោយឲ្យការរស់នៅល្បឿនលយទៅតាមយថាកម្ម ជាហេតុនាំឲ្យដុះនិស្ស័យខាងទុទ្ទិដ្ឋិ ។ ជនខ្លះបួលចិត្តបន់ស្រន់រៀបពលីការ បុស្សូត្រមន្តលំដោះគ្រោះ លើកជតាពសី ។ ប្រសិនបើប្រព្រឹត្តដូច្នេះទៅបានផលដូចចិត្តបំណងមែន ក៏ឃើញជាការងាយណាស់ មនុស្សលោកនឹងក្លាយទៅជាវិមានទិព្វទៅហើយ ។

**៣ – ជោគគឺអ្វី.**– បើយើងប្រើសេចក្តីសង្កេតមើលអ្នកជិតខាងយើងទៅ យើងនឹងបានដឹងថា ជនគ្រប់រូបពុំមានឋានៈ, និស្ស័យ, សមត្ថភាពនឹងទ្រព្យសម្បត្តិដូច ៗ គ្នាពីកំណើតមកទេ ទើបមានដំណើរជីវិតប្រព្រឹត្តផ្សេង ៗ គ្នា ខ្លះបានប្រកបដូចសេចក្តីប្រាថ្នាដោយស្រួល ខ្លះបានដោយលំបាក ខ្លះទៀតឃ្លាងរហូត ។ ដូច្នេះឃើញថាជនពួកមួយមានសំណាងជាងជនពួកមួយទៀត ។

ទោះបីបើដូច្នោះ សេចក្តីសម្រេចផល សម្រេចប្រយោជន៍ មកតែអំពីសេចក្តីព្យាយាមតែម្យាងប៉ុណ្ណោះ ។ ប្រវត្តិរូបមហាបុរសនឹងជនជាមហាសាលខ្លះ បញ្ជាក់ឲ្យឃើញស្តែងថា អស់លោកទាំងនោះចាប់កសាងជីវិតរបស់លោកតាំងពីកាលនៅជាជនសាមញ្ញ ឬជាជនទាល់ក្រ

តែដោយសារកំឡាំងសេចក្ដីប្រឹងប្រែង សេចក្ដីព្យាយាមឥតរួញរាពាន ពារឧបស័គ្គច្រើនចំពូក ទើបសម្រេចផលដូចចិត្តបំណង រហូតដល់សម្រេចហួសសេចក្ដីផ្គូផ្គងទុកផងទៀត ។ ប្រវត្តិដែលយើងស្គាល់ជាក់នោះ គឺប្រវត្តិលោក ឌ្រុអ៊ូត៍ ដែលជាកូនអ្នកលក់ទំប៉ុងដុនដាបបំផុត ។ លោកខំប្រឹងរៀនសូត្រតែដោយសារពន្លឺឡ្យ ឬពន្លឺព្រះចន្ទ ។ ពេលចូលដេញប្រយោគ និស្សិតដទៃនាំគ្នាចំអកឲ្យ មិនមាននរណាជឿថាកុមារទុព្វលភាពនោះមានសតិបញ្ញាវាងវៃឡើយ ស្រាប់តែកុមារនោះប្រឡងជាប់បានលេខ ១ នាំឲ្យគេស្ងើចគ្រប់គ្នា នេះហើយជាឧទាហរណ៍ឲ្យឃើញថា សេចក្ដីព្យាយាមអាចនាំនូវជោគល្អមកឲ្យបានពិតប្រាកដ ។

បុរាណាចារ្យប្រដៅថា "បេះមកពីរៀនបានមកពីរក" គឺថាបញ្ញាក្ដី ទ្រព្យសម្បត្តិក្ដី កេរ្តិ៍ឈ្មោះក្ដី សុទ្ធតែកើតមានឡើងដោយសេចក្ដីខំប្រឹងប្រែងទាំងអស់ ។ អ្នកជំនួញចិនដែលសម្រេចផលបានឡើងជាមហាធំនោះ តែងចាប់ការរកទទួលទានដោយមានតែខោលើជង្គង់ជាច្រើនគ្នា ។ ចំណែកខាងចំណេះវិជ្ជាវិញ ប្រសិនបើយើងសង្វាតអានសៀវភៅនៅផ្ទះ សង្វាតសង្កេត សង្វាតពិចារណា សង្វាតស្ដាប់ សង្វាតសាកសួរ ក៏គង់អាចចំរើនបាន ល្មមគួរយកទៅប្រើប្រាស់ជាប្រយោជន៍បាន ។

ដូច្នេះជាគរសនា នៅត្រង់សេចក្តីព្យាយាមហ្វឹកហ្វឺនចំរើនគុណ-សម្បត្តិនិងសមត្ថភាព ដែលនៅក្នុងខ្លួនយើងឲ្យលូតលាស់ចេញជាផ្កាឡើង ។

**៤ - ផលសម្រេច ឬជ័យជំនះនៅត្រង់ណា?** - ចុះផលសម្រេចឬជ័យជំនះនៅត្រង់ណា? សូមទាញឧទាហរណ៍មួយជាគ្រឿងអាងសិន ។

ឧបមាថា យើងត្រូវការជីកអណ្តូងយកទឹកប្រើប្រាស់ ការបានទឹកចេញពីកន្លែងដែលយើងបានជីក ហើយទឹកនោះសមប្រកបដល់ការប្រើប្រាស់តាមសេចក្តីប្រាថ្នាផង ទុកជាផលសម្រេច ។ ផលសម្រេចនេះបានឈ្មោះថាជ័យជំនះ ព្រោះឈ្នះនិស្ស័យខ្ជិលច្រអូស ឈ្នះធម្មជាតិហួតហែង ឈ្នះដីដែលបិទទឹកមិនឲ្យផុសជាប្រយោជន៍ ។ ផលសម្រេចស្ថិតក្នុងការប្រកបព្រមរវាងចេតនានិងការប្រព្រឹត្តិ ; ប្រាថ្នាចង់បានអ្វី ខំប្រឹងធ្វើឲ្យបានដូចសេចក្តីប្រាថ្នានោះឡើង ឬព្យាយាមកំចាត់បង់នូវឧបសគ្គដែលបិទផ្លូវ ដែលរាំងរកមិនឲ្យដើរឆ្ពោះទៅកាន់វត្ថុបំណង ។ ជីវិតគឺការរស់នៅរបស់យើង នឹងលូតលាស់ដុះដាលដូចធម្មជាតិបាន គោងប្រកបដោយការតស៊ូឥតស្រាក តស៊ូនឹងខ្លួនយើងដើម្បីកំចាត់បង់នូវនិស្ស័យអាក្រក់ដែលដេកត្រាំក្នុងសន្តាន ហើយនឹងបណ្តុះចំរើននូវកំឡាំងល្អដែលពួនសម្ងំក្នុងខ្លួនយើង ។ កាលឈ្នះខ្លួនហើយ គោងតស៊ូ

និងឧបសគ្គខាងក្រៅដែលជាគ្រឿងដំណាស់ ជាស្រេចលើសេចក្ដីប្រាថ្នា សេចក្ដីត្រូវការរបស់យើងទៀត ។ សម្រេចសេចក្ដីទៅ ដោគលាភឬសំណាងមិនមែនជារបស់កើតឯង ឬអានុភាពឯណាផ្ដល់ឲ្យទេ ជាកំឡាំងដែលនៅក្នុងខ្លួនរបស់យើង ហើយដែលយើងបេះបណ្ដុះបណ្ដាលឲ្យកើតប្រយោជន៍ដល់យើង ដោយសេចក្ដីព្យាយាមតស៊ូតតសោយ ។

៥ – **យើងត្រូវការប្រាថ្នាចង់បានអ្វី?** – មនុស្សគ្រប់រូបតែងមានចិត្តខុស ៗ គ្នា មានសេចក្ដីត្រូវការខុសគ្នា ទៅតាមសេចក្ដីនិយម សេចក្ដីជឿប្រកាន់និងឧត្ដមគតិរៀងខ្លួន ។ លោកគ្រូពេទ្យ រិចទ័រប៉ូសេត៍ បានឲ្យខ្ញុំថា: –

"អ្នកត្រូវការអ្វី? ចង់បានសុខ ។ ធ្វើម្ដេចទើបបានសុខ? ត្រូវបរិបូណ៌ដោយសុខភាព ជ័យជំនះ និងសេចក្ដីរីករាយជ្រះថ្លាក្នុងការធ្វើប្រយោជន៍ដល់អ្នកដទៃ ។ ធ្វើម្ដេចនឹងបានសុខភាពសម្បូរល្អ? ត្រូវប្រតិបត្តិតាមបញ្ញត្តិអនាម័យខាងកាយនិងខាងចិត្ត ។ ធ្វើម្ដេចនឹងមានជ័យជំនះក្នុងជីវិត? ត្រូវបរិបូណ៌ព្រមដោយគុណសម្បត្តិក្នុងសង្គម ឬដោយមេត្តានុភាព ។ សេចក្ដីត្រិះរិះពិចារណា, មនសិការ:, សាមគ្គីធម៌, កំឡាំងយកឈ្នះ, សេចក្ដីព្យាយាម គុណសម្បត្តិទាំង ៥ ប្រការនេះមានព្រមក្នុងខ្លួនអ្នកណាហើយ អ្នកនោះឈ្មោះថានឹងបានសម្រេចផលដោយពិត និងមានឋានៈខ្ពង់ខ្ពស់" ។

កាលបើយើងជាម្ចាស់នៃជោគរបស់យើង ជាជាងប្រសិទ្ធនូវជីវិតរបស់យើងដោយខ្លួនយើងហើយ យើងត្រូវប្រើសេចក្ដីព្យាយាមគ្រប់ពេលវេលា ដើម្បីសេចក្ដីសម្រេចផល សេចក្ដីសុខ សេចក្ដីរុងរោចន៍ ។ ទោះបីប៉ះទង្គិចសេចក្ដីលំបាកយ៉ាងណា យើងមិនគប្បីលះបង់សេចក្ដីព្យាយាមចោលទេ គួរទទួបបង្កើនមានះខំប្រឹងតទៅទៀត ។ និស្ស័យរបស់មនុស្ស មិនមែនជាការៈដែលគេកែផ្លាស់ប្ដូរមិនបាននោះទេ ដូចជាគេអាចផ្សាំ, បំប៉ៅ, បណ្ដុះ សំរិតសម្រាំងពូជឈើបានយ៉ាងណា គេក៏អាចដុសខាត់និស្ស័យឲ្យបានល្អយ៉ាងនោះដែរ ។

ហេង - យ៉ាន់

---

ជោគលាភ តែងចូលទៅរកបុរសសីហៈ ដែលជាអ្នកមានព្យាយាមក្លៀវក្លា, មានតែបុរសគ្រមក់ទេតែងពោលថា "ស្រេចតែព្រេងសំ-ណាង" · បុគ្គលបួរផ្ចាញ់វាស្នា ហើយធ្វើនូវព្យាយាមឲ្យពេញជាកូនប្រុសតាមកម្លាំងខ្លួនដែលអាចធ្វើបាន ។

រថ មិនអាចទៅបានដោយកង់តែមួយយ៉ាងណា ព្រេងវាស្នា បើវៀរចាកព្យាយាមនៃបុរសហើយ ក៏មិនសម្រេចយ៉ាងនោះដែរ ។

ហិតោបទេស

# អត្ថលោមត្យាជិបព្វាយ

១ – ឃើញមេឃងងឹតកុំគិតថប់ តាំងចិត្តឲ្យស្ងប់ស្រស់ក្រៃ
ឃើញផ្ទះរលំកុំសោកា គិតស្ថាបនាឡើងជាថ្មី ៗ
ឃើញភាពខ្លួនជួនវិបត្តិ វិនាសខ្ចាយខ្ចាត់បាត់រស្មី
កុំគិតតែស្តាយគ្មានធ្វើអ្វី ខំសាងផ្កាយថ្មីស្រស់បញ្ចង់ ៗ

២ – មុនឡើងផ្ទះថ្មីខ្ចីសំអាត មន្ទិលជាខ្នាតធូលីផង
ជំរះទាំងចិត្តឲ្យផុតផង់ ជំរង់ឲ្យល្អទើបគេមកក្សាន្ត ៗ
ទីវណាធម៌ច្រើនកុះករ យោគាវចរត្រូវក្លាហាន
សំឡាប់កាប់ផ្កាយោងយកឈាន ទើបចិត្តសម្រាន្តបានសុខា ៗ

៣ – តែទុកចិត្តណាស់ច្រើនខុសក្បួន មិនទុកចិត្តខ្លួនច្រើនខូចការ
ទោះទាំងផ្លូវលោកផ្លូវធម៌អាថ៌ ពិចារណាច្បាស់ទើបប្រសើរ ៗ
ធម្មតាជាតិមនុស្សសំគាល់ក្រ ក្នុងខ្មៅក្រៅសច្រើនដំណើរ
ត្រូវមើលកិរិយាអាការប្រើ ឃើញល្អសូមផ្ញើខ្លួនមុនមាំ ៗ

៤ – គេស្គាល់សង្គ្រាមដោយដកទូត គេស្គាល់ឈើលូតដោយថែទាំ
គេស្គាល់សត្វខ្លាចង្កូមមាំ គេស្គាល់ផ្កាំខាំដោយស្ងៀមស្ងាត់ ៗ
គេស្គាល់ខ្លួនឯងរៀងកម្រ មនោខ្មៅសធ្វេសប្រយ័ត្ន
ពាលប្រាជ្ញបណ្ឌិតចិត្តប្រណិប័តន៍ ពោះវៀនបត់កាត់ខ្លួនបង្កង ៗ

(មា៩៣) ក្រមការ ភ័យ-ប៊ុក

បញ្ចតន្ត្រៈ (តមកា)

ពេលនោះ, មានចចកពីរ មួយឈ្មោះករដកៈ មួយទៀតឈ្មោះទមនកៈ ជាកូនមន្ត្រីចាស់នៃសីហៈនោះ ដោះដោររត់ទៅនៅក្នុងព្រៃអាស្រ័យនៅចិញ្ចឹមជីវិត ។ ចចកទាំងពីរនោះគិតគូរពិគ្រោះគ្នា, ចចកឈ្មោះទមនកៈនិយាយថាៈ "នែសំឡាញ់ករដកៈ! បិង្គលកៈម្ចាស់យើងចុះទៅកាន់ទន្លេយមុនាដើម្បីផឹកទឹក ហេតុអ្វីក៏ស្រាប់តែត្រឡប់ឡើងមកវិញ? ហេតុអ្វីក៏រៀបចំព្យូហៈត្រៀមចាំនៅក្រោមដើមជ្រៃនេះ?" ។ ចចកករដកៈឆ្លើយថាៈ "នែសំឡាញ់ទមនកៈ! រឿងនេះមិនមែនការងារយើងទេ យើងមិនត្រូវរវល់ដឹងគ្នាទេ, ព្រោះថាៈ—

២១— នរជនណា ជួញចិត្តរវល់ ក្នុងការដែលមិនត្រូវរវល់ នរជននោះ តែងដល់នូវសេចក្ដីវិនាស ដូចពានរដោះខ្លួនព្រោះចាប់ទាញឈើស្នៀត" ។

ទមនកៈសួរថាៈ "រឿងនេះតើដូចម្ដេច?" ។ ករដកៈរៀបរាប់រឿងនោះប្រាប់ថា

កថាទី ២

## រឿងពានរនឹងសសរ

មានទីឋានមួយតាំងនៅជិតក្រុង បុគ្គលពាណិជម្នាក់ បានផ្ដួលផ្ដង ឡើងសាងទេវស្ថាននៅកណ្ដាលព្រៃឈើធំ ។ ក្នុងទីឋាននោះ មេ

ជាងនឹងកម្មករទាំងឡាយ តែដល់ពេលថ្ងៃត្រង់ តែងនាំគ្នាចូលទៅកាន់ក្រុងដើម្បីបរិភោគអាហារ ។ ពេលនោះ មានហ្វូងស្វាមួយហ្វូងធំ វារលោតលេងពីដើមឈើមួយទៅដើមឈើមួយដែលឋិតនៅជាប់ៗគ្នា ទៅខាងនេះម្ដងខាងនោះម្ដង រហូតមកដល់ទីឋាននោះ ។ នៅទេវស្ថានដែលកំពុងកសាងនោះ មានសសរមួយធ្វើពីដើមអញ្ចាន ព្រឹក្ស មេជាងបង្គាប់ឲ្យអារពុះពាក់កណ្ដាល ហើយឲ្យស៊កស្នៀតឈើគគីរ ១ ទុកបំពាក់កណ្ដាលសសរដែលពុះនោះ ។ ក្នុងពេលនោះឯង ពួកពានរទាំងឡាយ ដែលឡើងមកលោតលេងលើចុងឈើនឹងលើទេវស្ថាន ក៏ឡើងមកលើចុងសសរតាមអំពើចិត្តទៀត ។ បណ្ដាសត្វស្វាទាំងឡាយនោះ មានស្វាមួយដែលមុត្សរចូលមកជិតហើយ ឡើងទៅអង្គុយលេងឥតពិចារណា លើចុងសសរដែលគេស៊កស្នៀត ធ្លាក់ប្រោកខ្លួនយារស្ដោកទៅចំបន្ទោះដែលគេពុះពាក់កណ្ដាលនោះ ចាប់ទាញឈើស្នៀតដោយដៃទាំងពីរដោយក្ដីរពឹស របូតស្នៀតនោះចេញមកចុងសសរទាំងពីរក៏ក្ដោបមកគៀបប្រោកខ្លួនដល់ក្ដីស្លាប់ទៅហោង ដូចជារឿងដែលខ្ញុំប្រាប់សំឡាញ់នេះឯង ។

ព្រោះហេតុនោះ បានជាខ្ញុំពោលថា : "នរជនណា ផ្ចួញចិត្តរវល់" ដូច្នេះជាដើម (លេខ ២១) ។ យើងទាំងពីរនាក់ ចាំតែស៊ីអាហារដែលសេសសល់ពីម្ចាស់យើងស៊ីបានហើយ ចាំបាច់ទៅធ្វើរវល់ក្នុងរឿង

នោះធ្វើអ្វី? ។ ទមនកៈឆ្លើយថា: "បើដូច្នោះ ឯងមិនគិតតែពីស៊ីទៅហើយ ធ្វើដូច្នេះ មិនគួរទេ, ព្រោះថា:–

២២ – ការពឹងពាក់ព្រះនូបតី អ្នកប្រាជ្ញត្រូវការចង់បាន ដើម្បីធ្វើឧបការៈជួយមិត្រ នឹងដើម្បីបំផ្លាញសឹកសត្រូវ នរណាហ្ន៎ ពឹងពាក់ព្រះនូបតី ដើម្បីបំពេញផ្ទៃខ្លួនប៉ុណ្ណោះ?

២៣ – បើនរជនណា មានជីវិតរស់នៅ បានញ៉ាំងជនដទៃច្រើននាក់ឲ្យមានជីវិតរស់នៅបានផង នរជននោះ នឹងមានជីវិតរស់នៅយឺនយូរក្នុងលោកនេះ, រីបក្សីក៏មិនអាចបំពេញផ្ទៃខ្លួនក៏បានដោយចំពុះក៏ឬអ្វី?

២៤ – [១]ក្នុងលោកនេះ អ្នកណារស់នៅតែមួយស្របក់ តែប្រកបដោយសម្បទាដែលមនុស្សលោកប្រាថ្នា គឺ: ចំណេះវិជ្ជា សេចក្តីអង់អាចក្លាហាន ទ្រព្យសម្បត្តិ នឹងគុណដ៏ប្រសើរទាំងឡាយ, អ្នកដឹងការនោះច្បាស់លាស់ តែងពោលសរសើរជីវិតអ្នកនោះ ថាជាជីវិតដ៏ប្រសើរ, ឯសត្វក្អែករស់នៅបានយូរ ដោយគ្រាន់តែស៊ីបាយសល់អំពីគេធ្វើពលីកម្មបាន ។

---

១ បញ្ចតន្ត្រៈ សេចក្តីប្រែជាបារាំងនៃលោកឡង់ស៊ីរ្វ មានគាថាដូច្នេះទៀតថា អ្នកណាមិនប្រព្រឹត្តល្អចំពោះកូន ចំពោះគ្រូអាចារ្យ, ចំពោះញាតិសន្តាន ចំពោះអ្នកក្រីក្រ នឹងចំពោះបណ្ដាមនុស្សជាតិ បានកើតជាមនុស្សនេះ តើបានប្រយោជន៍អ្វី? សត្វក្អែករស់នៅបានយូរ ដោយគ្រាន់តែស៊ីបាយសល់អំពីគេធ្វើពលីកម្ម ។

២៥ – ស៊ីឆ្អែតពេញបានងាយ រន្ធកណ្ដុរពេញបានដោយងាយ, រីមនុស្សគម្រែកស្កប់ចិត្តបានដោយងាយ ហើយពេញចិត្តសប្បាយបានបន្តិចបន្តួច ៗ

២៦ – អ្នកណាកើតមកមិនបានលើកវង្សត្រកូលខ្លួនឲ្យខ្ពស់ ដូចទង់ជ័យលើកត្បូលផងតើ អ្នកនោះកើតមកម្ដងនឹងគេ តើបានប្រយោជន៍អ្វី? បានត្រាន់តែបំផ្លាញវ័យក្មេងនៃមាតាខ្លួនប៉ុណ្ណោះ ៗ

២៧ – ក្នុងសង្សារវដ្ដដែលប្រព្រឹត្តកន្លងទៅនេះ នរណាមួយស្លាប់ហើយ មិនកើតទៀត? ក្នុងលោកនេះ អ្នកណាធ្វើឲ្យកើតសេចក្ដីរុងរឿងក្នុងត្រកូលដោយក្រៃលែង អ្នកនោះ លោករាប់ថាកើតមែនទែន ៗ

២៨ – ស្មៅដែលដុះនៅក្បែរមាត់ស្ទឹង មានផលប្រយោជន៍ច្រើន ព្រោះនឹងបានជាទីពឹង ស្រាវតោងដោយដៃនៃនរជនដែលលង់ស្ទុះស្ទាក្នុងទឹក ៗ

២៩ – សប្បុរសប្រព្រឹត្តខ្លួនសុភាពរាបសាខ្ពង់ខ្ពស់ថ្លៃថ្នូរ នឹងបន្ទោបង់នូវសេចក្ដីក្ដៅក្រហាយនៃប្រជាជន កើតមានក្រណាស់ក្នុងលោកនេះ ដូចជាការកើតនៃពពកដែលចរទៅខ្ពស់ ហើយបរិបូណ៌ដោយទឹកផ្សព្វផ្សាយត្រជាក់ដូច្នោះឯង ៗ

៣០– កូនណា, សូម្បីអ្នកធំទាំងឡាយក៏គោរពបូជាដែរ អ្នកប្រាជ្ញលោករាប់ទុកថា មាតាដែលពរផ្ទៃនៃកូននោះ ជាមាតាដែលមានគុណធំ បុគ្គលគួរគោរពកន្លងមិនបាន ៗ (មា៩៣)

# សេចក្ដីថ្លែងការណ៍គណៈកម្មាធិការ

កាលពីថ្ងៃទី ៤ មិនា គ. ស. ១៩៥០ នេះ សមាគមមិត្តសាលាបាលី បានធ្វើពិធីប្រគេនទេយ្យវត្ថុដល់សិស្សចំនួន ៣៧ រូបដែលបានប្រឡងជាប់សញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ក្នុងឆ្នាំ ១៩៥០ ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ។

ពេលនោះរបៀងសាលាបាលី បានទទួលការរៀបចំយ៉ាងប្រណីតផ្ចិតផ្ចង់រលេចក្បូរក្បាច់ស្រស់បញ្ចង់ ដោយស្លឹកឈើខៀវខ្ចី រនាំងសំពត់ប្រស់រស្មីព្រះអាទិត្យដែលកំពុងក្ដៅខ្លាំងចាំងព្រិលភ្នែក ឲ្យភ្លឺត្រជាក់ល្អ ៗ កំរង់ផ្កាយ៉ាងធំមួយកំរង់អណ្ដែតត្រសែតចំកណ្ដាលទី ជាការលើកដំកើងពិធីបុណ្យឲ្យមានសេចក្ដីរុងរឿងយ៉ាងពិសេស ។ ផ្នែកខាងលិច ភិក្ខុសង្ឃជាច្រើនរូបប្រាលផ្អិនផ្អៅដោយពណ៌លឿង គង់លើកៅអីរង់ចាំទទួលសញ្ញាប័ត្រនិងទេយ្យវត្ថុនៅកណ្ដាលតុវែង ២ ជួរ ដែលមានសមាជិកសមាគមជាច្រើនរូបឈរអមពីក្រៅ ៗ នៅលើតុនោះ មានទេយ្យវត្ថុខ្ចប់ដោយក្រដាសសស្ទើរឃើញវត្ថុខាងក្នុង ហើយក្រប្លុបចុងជាក្បួ ចងអំបោះពណ៌ជម្ពូជាបូ រៀបជាជួរតាមលំដាប់លេខជារង្វាន់ ដែលអ្នកមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាបានចាត់ចែងជូនមកជាមួយនឹងសៀវភៅធម៌ ដែលជាអំណោយរបស់សមាគមនិងរបស់ក្រុមពុទ្ធសាសនបណ្ឌិត្យ ។ ផ្នែកខាងកើតជាកន្លែងប្រថាប់នៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង មួយអន្ទើដោយ

ឥស្សរជនជាច្រើន មានលោកនាយករដ្ឋមន្ត្រីជាដើម ។ តុំដំកល់សញ្ញាបត្រតាំងនៅកណ្ដាល ។ សម្ដេចព្រះសង្ឃនាយកគណៈធម្មយុត្តិ, សម្ដេចព្រះធម្មលិខិតឧត្តមប្រឹក្សា និងព្រះសង្ឃនាយកគណៈមហានិកាយ គង់ជាកិត្តិយសនៅខាងត្បូងតុនោះ ។

ពេលម៉ោង ១៦ លោកក៉យ-ប៊ុក អធិបតីសមាគមមិត្តសាលាបាលី បានសូត្រសុន្ទរកថាបើកពិធីបុណ្យ ។ ព្រះតេជព្រះគុណព្រះពោធិវង្ស បានថ្លែងសេចក្ដីតប ក្នុងនាមនៃសាលាបាលីជាន់ខ្ពស់ដែលលោកជាចាងហ្វាង ។ តមក ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ប្រទានផ្ទាល់ព្រះអង្គនូវសញ្ញាបត្រដល់សិស្សទាំងឡាយ ដោយទឹកព្រះភក្ត្រស្រស់បំព្រងផ្ទុះនូវបីតិបាមោជ្ជៈឲ្យចេញច្បាស់ប្រាកដ ។ ជាលំដាប់មក លោកសម-ញាណ បានសូត្រព្រហ្មទេយ្យចែករង្វាន់ ។ ជាបំផុតកិច្ច ព្រះករុណាជាអម្ចាស់ជីវិត បានផ្ដាមព្រះហស្តថ្លែងព្រះរាជអំណរចំពោះព្រះថេរានុត្ថេរៈនិងពួកពុទ្ធបរិសទ្យ សម្ដែងព្រះរាជហឫទ័យស្មោះចំពោះក្នុងកល្យាណកិច្ចនោះ និងក្នុងព្រះពុទ្ធសាសនា ។

លោកអធិបតីសមាគមមិត្តសាលាបាលីបានបញ្ជាក់នូវកិច្ចនាទីរបស់សាលាបាលីក្នុងសុន្ទរកថារបស់លោកថា:

"ព្រះពុទ្ធសាសនា ក្នុងកម្ពុជរដ្ឋ ដែលរុងរឿងរៀងរាបដរាបមក រហូតដល់មានកិត្តិសព្ទផ្សាយដល់ប្រទេសឥណ្ឌា ប្រទេសបារាំងជាដើម

បានដឹងពុំថាជារដ្ឋមានពុទ្ធសាសនាប្រតិស្ឋានមាំមួន នេះដោយអាស្រ័យវិទ្យាស្ថាន គឺសាលាបាលីជាន់ខ្ពស់ ដែលមានភិក្ខុសាមណេរជាសិស្ស បានបំពេញវិជ្ជាផ្លូវព្រះពុទ្ធសាសនាដោយមុឺងម៉ាត់ ។ សាលាបាលីជាន់ខ្ពស់នេះ ជាមរដកនៃល្អងធូលីព្រះបាទព្រះករុណាជាអម្ចាស់ជីវិតលើ-ត្បូង ទាំងជាកេរ្តិ៍កោះរបស់យើងទាំងឡាយ ដែលគួរស្ងួនគ្រងរក្សាទុកឲ្យខាងតែគង់វង្សជាអង្វែងទៅ ព្រោះសាលានេះ បុត្របុរសយើងបានបង្កើតឡើង ដើម្បីរក្សាទុកនូវព្រះពុទ្ធសាសនា, អក្សរសាស្ត្រខ្មែរ, វប្បធម៌ខ្មែរ នឹងប្រពៃណីខ្មែរ ជាភស្តុតាងបញ្ជាក់ភាពខ្មែរ ដែលមិនអាចរលាស់ចោលចេញ ឬលាក់បំពួនទៅបានឡើយ" ។ លោកបានលើកគោលបំណងនេតិធំបែកទេយ្យវត្ថុថា:

"ពេលវេលាជាមង្គល ដ៏មានអច្ឆរិយភាព របស់សមាគមមិត្តសាលាបាលីនេះ ជាគុណដ៏សំខាន់អាចនាំបណ្តាលឲ្យមានកិត្តិសព្ទបង្ហាញឲ្យឃើញច្បាស់ថា "ពុទ្ធសាសនាកម្ពុជរដ្ឋ ដែលមានសាលាបាលីជាន់ខ្ពស់ជាឃ្លាំងធំនេះ ពួកឥស្សរជនមិនមែនជាមើលមិនឃើញនូវសារប្រយោជន៍ ដូចអ្នកខ្លះធ្លាប់ស្មានមកនោះទេ" ព្រមទាំងជាគុណនាំបណ្តាលឲ្យពួកសិស្សសាលាបាលី ដែលទើបនឹងប្រឡងចេញនេះ កើតបីតិរីករាយផ្អែតចិត្ត ភ្លេចគិតដល់ការលំបាកនឿយហត់អត់ឃ្លាន ក្នុងពេលខំរៀននោះបានខ្លះ" ។

ព្រះតេជព្រះគុណព្រះពោធិវង្ស បានទុកពិធីចែកទេយ្យវត្ថុជាកល្យាណកិច្ចមួយដ៏ប្រសើរ មានប្រយោជន៍ច្រើនស្ថាន គឺនាំឲ្យសិស្សទាំងឡាយដែលប្រឡងចេញពីសាលាហើយ មានបីតិប្រាមោជ្ជគ្រប់រូប នឹងនាំឲ្យសិស្សក្នុងសាលាគ្រប់ថ្នាក់ក្នុងបច្ចុប្បន្ននឹងក្នុងអនាគត ខំប្រឹងប្រែងរៀនសូត្រមិនធ្វេសប្រហែស ដោយសំគាល់ថា ការរៀនសូត្រព្រះបរិយត្តិធម៌នេះ ជាហេតុដឹកនាំពុទ្ធមាមកជនទាំងឡាយឲ្យមានចិត្តត្រេកអរសោទរ ។ លោកបានរំឭកដាស់តឿនសិស្សថា:

"មិនត្រូវសំគាល់ថា ការសិក្សារៀនសូត្រនេះសម្រេចចប់ត្រឹមតែបានទទួលសញ្ញាប័ត្ររបស់សាលាប៉ុណ្ណោះឡើយ ហើយបោះបង់ចោលលែងរវល់តទៅទៀតដូច្នេះទេ គឺត្រូវតែខំប្រឹងប្រែងសិក្សាដោយខ្លួនយើងតទៅទៀត ព្រោះបំណេះក្នុងសាលា គ្រាន់តែជាមធ្យោបាយបង្ហាញផ្លូវឲ្យសិស្សចេះដើរ ចេះប្រើប៉ុណ្ណោះ ត្រូវតែខំប្រឹងរៀន ខំប្រឹងស្រាវជ្រាវរករក ខំប្រឹងពិនិត្យពិចារណាកត់ត្រាដោយខ្លួនយើងតទៅទៀត ទើបបំណេះវិជ្ជាដែលបានរៀនសូត្រមកហើយនោះ អាចចំរើនល្អតលាស់ឡើងបាន; លុះការសិក្សាបានចំរើនឡើងហើយ ត្រូវបង្ហាត់កាយវាចាចិត្តឲ្យសមតាមធម៌តាមច្បាប់ថែមទៀត ទើបសមភាពជាបណ្ឌិតជាតិ ហើយអាចទទួលភារៈធ្វើការស្នងគុណអាចារ្យជាលំដាប់តទៅ" ។

IMPRIMERIE ROYALE